សុន្ទរកថារបស់ **ឯកឧត្តម លោក ម៉ាសាហ្វ៊ូមី** ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព
របស់ប្រទេសជប៉ុនប្រចាំកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន

១៦ មករា ២០១២

**សូមគោរព លោក ប៉ូច ពាង មេឃុំស្ពៅ**
**សូមគោរព លោក ម៉ូរី តេស៊ីអ៊ុ អ្នកតំណាងប្រចាំប្រទេស អង្គការ** Good Earth Japan!
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលមានវត្តមានក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយថ្ងៃនេះ ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដែលពេលនេះផ្តល់ជូនអង្គការGood Earth Japan។

ជាមួយជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុននេះ អង្គការ “Good Earth Japan” នឹងសាងសង់ផ្លូវកសិកម្មដែលមានប្រវែង៣.៤គ.ម ក្នុងភូមិគោកជរ និង ភូមិអណ្តើក១១ ឃុំស្ពៅ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង។

ក្នុងឆ្នាំ២០០៨ រដ្ឋាភិបាលជប៉ុនបានផ្តល់ជំនួយដើម្បីគាំទ្រដល់ការបោសសំអាតមីន រួមទាំងតំបន់គម្រោងប្រមាណ២៤០ហិចតាដែលអង្គការ ជី អ៊ី ជេ បានជួយគាំទ្រក្នុងការកែប្រែឲ្យទៅជាដីកសិកម្ម និង ផ្តល់នូវបច្ចេកទេសកសិកម្ម ព្រមទាំងកសាងហេដ្ឋារចនាសម្ព័ន្ធ។ ប៉ុន្តែខ្ញុំបានឮថានៅតំបន់នោះគ្មានផ្លូវថ្នល់ដែលមានសភាពល្អនោះទេ។ នៅរដូវវស្សា ផ្លូវក្លាយជាភក់ដែលពិបាកក្នុងការដឹកជញ្ជូនឥវ៉ាន់ និងធ្វើកសិកម្ម។ ប្រជាជនដែលរស់នៅតំបន់នោះត្រូវចំណាយពេលប្រហែលមួយម៉ោងដើម្បីធ្វើដំណើរទៅកាន់ដីស្រែរបស់ពួកគេ ហើយអ្នកភូមិមួយចំនួនមិនអាចធ្វើកសិកម្ម បានបើទោះជាពួកគេមានដីក៏ដោយ។

តាមរយៈការអនុវត្តគម្រោងដែលជាជំនួយអភិវឌ្ឍផ្លូវការរបស់ជប៉ុននេះ ប្រសិទ្ធភាពនៃការងារកសិកម្ម និង ការចែកចាយកសិផលនឹងកើនឡើង ។ ខ្ញុំសង្ឃឹមថាវាផ្តល់អត្ថប្រយោជន៍ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនក្នុងតំបន់ចំនួនជាង៨០០នាក់។

ក្នុងគម្រោងនេះ “ជី អ៊ី ជេ” រួមនិងរដ្ឋបាលតំបន់ នឹងសហការគ្នារៀបចំសិក្ខាសាលាដើម្បីណែនាំប្រជាជនក្នុងតំបន់ពីការថែរក្សាផ្លូវ។ ខ្ញុំឮថាគណកម្មាការដែលបង្កើតឡើងដោយប្រជាជន នឹងថែរក្សាផ្លូវនេះជារៀង

រាល់ថ្ងៃ។ ដោយសារផ្លូវនេះជាផ្លូវក្រួសក្រហមដែលទាមទារការថែរក្សាច្រើន ខ្ញុំសង្ឃឹមថាប្រជាជននឹងចូលរួមក្នុងការថែរក្សាផ្លូវមិនត្រឹមតែក្នុងពេលបច្ចុប្បន្ន ប៉ុន្តែជារៀងរហូតទៅ។ ខ្ញុំរំពឹងទុកថាតាមរយៈសិក្ខាសាលា ប្រជាជនក្នុងតំបន់នឹងយកចិត្តទុកដាក់ និងដើរតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សាផ្លូវ។

ជាងនេះទៅទៀត ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខានៅថ្ងៃនេះនឹងផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់ប្រជាជននៅថ្នាក់មូលដ្ឋាន និងលើកស្ទួយជាបន្តទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!